នស/រកត/០៨០១/២៨៩

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បង្កើត "**ក្រុមប្រឹក្សាកីឡាកម្ពុជា**" ចំណុះរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២** : ក្រុមប្រឹក្សាកីឡាកម្ពុជា មានសមាសភាព ដូចខាងក្រោម ៖

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រី | អនុប្រធាន |
| ៣- រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិកអចិន្ត្រៃយ៍ |
| ៤- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក ។ ល ។ |

Downloaded from http://www.khmerlaws.com

៩- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

១០-រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក

១១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល សមាជិក

១២-រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សមាជិក

១៣-រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក

១៤-ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិក

១៥-ប្រធានគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា សមាជិក

១៦-អគ្គនាយក នៃអគ្គនាយកដ្ឋានយុវជន និងកីឡា សមាជិក

១៧-ប្រធានគ្រប់សហព័ន្ធកីឡាជាតិ សមាជិក

មាត្រា ៣ : ភារកិច្ច និងសិទ្ធិរបស់ក្រុមប្រឹក្សាកីឡាកម្ពុជា :

- ក្រុមប្រឹក្សាកីឡាកម្ពុជា មានភារកិច្ចសម្របសម្រួល ណែនាំ ជួយជំរុញឧបត្ថម្ភ និងលើកស្ទួយវិស័យកីឡាជារួម និងវិស័យកីឡានិមួយៗ នៃព្រះរាជាណាចក្រកម្ពុជា
- ក្រុមប្រឹក្សាកីឡាកម្ពុជា មានសិទ្ធិបង្កើតក្រុមប្រឹក្សាកីឡាខេត្ត-ក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា
- ក្រុមប្រឹក្សាកីឡាកម្ពុជា មានសិទ្ធិប្រើប្រាស់ថវិកា និងត្រា របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សមាជិកក្រុមប្រឹក្សាកីឡាកម្ពុជា ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន
- ទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវធ្វើជាសេនាធិការផ្ទាល់អោយក្រុមប្រឹក្សាកីឡាកម្ពុជា ។

មាត្រា ៤ : នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេច ព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។ល។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ១៩៣ ច.ល

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ សីហា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៧ ខែ ៨ ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

Downloaded from http://www.khmerlaws.com